## រាជបណ្ឌិត្យសភាកម្ពុជា
## វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

### អត្ថបទស្រាវជ្រាវ

# ការប្រតិបត្តិសាសនា និងជំនឿអ្នកតា
# នៅក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តកែវ






**ដោយ លោកស្រី សរ សិលា**

**អនុប្រធានផ្នែកសិល្បៈនិងឥស្សរិយយសនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ**


**ខែមីនា ឆ្នាំ២០១៩**

# ការប្រតិបត្តិសាសនា និងជំនឿអ្នកតា
# នៅក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ

## សេចក្តីផ្តើម

ប្រទេសកម្ពុជាតាំងពីសម័យដើមរៀងយើងសង្កេតឃើញថា ប្រជាជនមានជំនឿ ប្រពៃណី និងទំនៀមទម្លាប់សម្រាប់សម្គាល់អត្តសញ្ញាណរបស់ជាតិសាសន៍ខ្លួនយ៉ាងច្បាស់លាស់ ដែលអត្តសញ្ញាណទាំងនោះបានបង្ហាញឱ្យពិភពលោកឃើញនិងយល់ពីកម្ពុជាផងដែរតាមរយៈពិធីផ្សេងៗដូចជាការគោរពប្រតិបត្តិនៅក្នុងសាសនាមានដូចជាពិធីបុណ្យសព បុណ្យចូលឆ្នាំ បុណ្យពិសាខបូជា បុណ្យមាឃបូជា បុណ្យផ្កា បុណ្យកឋិន បុណ្យភ្ជុំបិណ្ឌ ពិធីរៀបអាពាហ៍ពិពាហ៍ និងការមានជំនឿគោរពទៅលើអ្នកតាម្ចាស់ស្រុកឬឥទ្ធិពលផ្សេងៗរបស់ប្រជាជនខ្មែរជាដើម។

នៅក្នុងការប្រតិបត្តិសាសនា ព្រះពុទ្ធសាសនាត្រូវបានលើកតម្កើងជាសាសនារបស់រដ្ឋ ប៉ុន្តែប្រជាជនខ្មែរទូទៅទទួលបាននូវសិទ្ធិសេរីភាពយ៉ាងពេញលេញនៅក្នុងជំនឿ និងការប្រតិបត្តិនូវសាសនាផ្សេងៗ។ ជាក់ស្តែងដូចជាជំនឿ និងពិធីផ្សេងដែលទាក់ទងនឹងសាសនាដទៃ ជាពិសេសព្រហ្មញ្ញសាសនាគឺនៅតែបន្តមានក្នុងផ្នត់គំនិតប្រជាជនខ្មែរតាំងពីសម័យដើមរហូតដល់សម័យបច្ចុប្បន្ននេះផងដែរ គ្រាន់តែជំនឿ និងការគោរពប្រតិបត្តិសាសនារបស់ប្រជាជនមិនដូចគ្នាទាំងស្រុងឡើយ គឺអាចមានការខុសគ្នាខ្លះៗទៅតាមតំបន់ ឬទីកន្លែងដែលពួកគេរស់នៅ។ ពោលគឺ ការប្រតិបត្តិសាសនារបស់ប្រជាជនខ្មែរនៅក្នុងប្រទេសអាចមានការខុសគ្នាពីការប្រតិបត្តិសាសនារបស់ប្រជាជនខ្មែរនៅឯក្រៅប្រទេស ហើយការប្រតិបត្តិសាសនារបស់ប្រជាជនក្នុងប្រទេសទៀតសោតក៏អាចមានការខុសគ្នាពីខេត្តមួយទៅខេត្តមួយ ពីស្រុកមួយទៅស្រុកមួយ ពីឃុំមួយទៅឃុំមួយ និងពីភូមិមួយទៅភូមិមួយទៀតដែរ ចំណែកជំនឿទៅលើអ្នកតាក៏បែបនេះដែរ គឺដូចគ្នាទៅនឹងការធ្វើម្ហូបអាហារ ដែលមុខម្ហូបដូចគ្នាតែមានការហៅ និងរបៀបធ្វើខុសគ្នាពីតំបន់មួយទៅតំបន់មួយដូច្នោះដែរ។

ផ្ទុយទៅវិញអ្វីដែលដូចគ្នា គឺផ្នត់គំនិត ដែលមានចំពោះសាសនា និងជំនឿទៅលើអ្នកតាវានៅតែអត្ថិភាពក្នុងស្មារតីរបស់ប្រជាជនខ្មែររហូតមក។

ជាក់ស្តែងតាមការសិក្សាស្រាវជ្រាវរបស់ក្រុមស្រាវជ្រាវអំពី មរតកវប្បធម៌រូបី និងអរូបីនៅក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ដែលជាទឹកដីដ៏ចំណាស់ និងមានកេរដំណែលវប្បធម៌ទាំងរូបីនិងអរូបីយ៉ាងច្រើននោះ យើងក៏ឃើញពីភាពរួមនិងភាពដោយឡែកនៅក្នុងការប្រតិបត្តិសាសនា និងជំនឿអ្នកតារបស់ភូមិនីមួយៗដែរ។ ផ្តើមពីការមើលឃើញបែបនេះ ទើបខ្ញុំមានការចាប់អារម្មណ៍ធ្វើការសិក្សាពី ***ការប្រតិបត្តិសាសនា និងជំនឿអ្នកតានៅភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ***។

ដូច្នេះ តើភូមិព្រៃខ្វាវមានស្ថានភាពភូមិសាស្ត្រយ៉ាងដូចម្តេច? តើជីវភាពរស់នៅរបស់ប្រជាជនមានខ្លះ? តើការប្រតិបត្តិសាសនា និងជំនឿអ្នកតានៅភូមិព្រៃខ្វាវមានលក្ខណៈបែបណា? តើសាកលភាវូបនីយកម្មបានជះឥទ្ធិពលអ្វីខ្លះដល់ការរស់នៅ ព្រមទាំងការប្រតិបត្តិសាសនា និងជំនឿរបស់ប្រជាជនក្នុងភូមិព្រៃខ្វាវ?

## ១- ទិដ្ឋភាពទូទៅនៃភូមិព្រៃខ្វាវ

ភូមិព្រៃខ្វាវ គឺជាភូមិដ៏ចំណាស់មួយនៅក្នុងចំណោមភូមិទាំង១១ របស់ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ។ ភូមិនេះស្ថិតនៅតាមបណ្ដោយផ្លូវជាតិលេខ១៣២អា មានទំហំផ្ទៃដីសរុបចំនួន៧២ហិកតា និងមានប្រជាជនចំនួន៩៩គ្រួសារ ដែលគិតជាចំនួនមនុស្សមាន៤៧៦នាក់ គឺស្រីចំនួន២៦២នាក់ ប្រុសចំនួន២១៤នាក់។ ប្រជាជនភូមិព្រៃខ្វាវភាគច្រើន គឺមានអាយុចាប់ពី១៨ឆ្នាំដល់អាយុ៥០ឆ្នាំជាង ហើយវ័យដែលមានអាយុចាប់ពី៦០ឆ្នាំឡើងទៅគឺមានចំនួនតិច ឯអាយុ៧០ឆ្នាំដល់៨០ឆ្នាំ គឺមានប្រហែល១០នាក់។

ប្រសិនបើយើងសម្លឹងទៅមើលព្រំប្រទល់របស់ភូមិវិញ យើងឃើញថា ភូមិព្រៃខ្វាវគឺមានព្រំប្រទល់ខាងត្បូងជាប់ទៅនឹងភូមិប៉ាគៀបរបស់ឃុំត្រពាំងធំខាងត្បូង រីឯព្រំប្រទល់ខាងជើងជាប់ជាមួយភូមិតាសួន ព្រំប្រទល់ខាងលិចជាប់ជាមួយភូមិត្រពាំងស្វាយ និងព្រំប្រទល់ខាងកើតជាប់ជាមួយភូមិព្រៃតាឡី ដែលភូមិទាំងបីខាងក្រោយនេះគឺសុទ្ធតែស្ថិតក្នុងឃុំត្រពាំងធំខាងជើងទាំងអស់។

### ១.១- ដើមកំណើតទាក់ទងនឹងឈ្មោះរបស់ភូមិព្រៃខ្វាវ

ចំពោះរឿងរ៉ាវដែលទាក់ទងទៅនឹងភូមិព្រៃខ្វាវនេះ មានការដំណាលតៗគ្នាថា កាលពីដើមឡើយក្នុងភូមិនេះមានដុះសុទ្ធតែដើមខ្វាវហើយជាព្រៃខ្វាវព័ទ្ធជុំជិតតែម្តង ប៉ុន្តែព្រៃខ្វាវនេះត្រូវបានគេកាប់អស់តាំងពីយូរណាស់មកហើយ គឺប្រហែលជានៅសម័យសម្តេចសីហនុខ្ទង់ឆ្នាំ១៩៦៨មកម៉្លេះ ដោយសារប្រជាជនចង់បានដីធ្វើស្រែចម្ការ ដាំដំណាំ និងសង់លំនៅដ្ឋាន។ ដូច្នេះទើបគេនាំគ្នាហៅភូមិនេះថា ភូមិព្រៃខ្វាវរហូតមកដល់សព្វថ្ងៃ ហើយបច្ចុប្បន្នភូមិនេះមានកន្លែងខ្លះក៏នៅមានដើមខ្វាវដុះខ្លះដែរ។[1]

នៅសម័យសម្តេចសីហនុប្រជាជនភូមិព្រៃខ្វាវធ្លាប់មានការប្រមូលភូមិដែរ។ ការប្រមូលភូមិនេះ គឺគេធ្វើការប្រមូលប្រជាជនពីក្នុងភូមិឱ្យមូលទៅនៅតាមដួរថ្នល់ជុំគ្នា។ ចំពោះមូលហេតុនៃការប្រមូលភូមិនេះ គឺដោយសារជំនាន់នោះមានពួកឥស្សរៈ និងចោរប្លន់ចេះតែមកអុកឡុក ប្លន់អ្នកភូមិពេក ហេតុដូច្នេះរដ្ឋអំណាចថ្នាក់ខេត្តក៏បញ្ជាឱ្យមេស្រុក មេឃុំ មេភូមិប្រមូលប្រជាជនទៅនៅតាមថ្នល់ប្រហែល១០០ម៉ែត្រពីកន្លែងនេះ(ភូមិបច្ចុប្បន្ន) ហើយយប់ឡើងឱ្យប្រជាជនទៅដេកជុំគ្នាដួរថ្នល់ ចំណែកពេលភ្លឺឡើងនាំគ្នាទៅធ្វើការតាមស្រែចម្ការរៀងៗខ្លួន។ ក្នុងកំឡុងពេលប្រមូលភូមិនេះ ជួនកាលពួកឥស្សរៈបានឡើងមកម្តងៗដើម្បីសុំយកអង្ករទៅដាំបាយ។



ដើមខ្វាវដែលដុះនៅជិតផ្ទះអ្នកភូមិ

[1] **អម អូន** អាយុ៧៥ឆ្នាំ ដែលជាចាស់ព្រឹទ្ធាចារ្យកើតនៅក្នុងភូមិព្រៃខ្វាវ(សម្ភាសន៍ ថ្ងៃ១៥ សីហា ២០១៦)

លោកមេភូមិព្រៃខ្វាវ **ប្រាក់ ណន** បានបញ្ជាក់ថា បើតាមឪពុករបស់គាត់និយាយប្រាប់ការប្រមូលភូមិក្នុងភូមិព្រៃខ្វាវនេះ គឺធ្វើឡើងនៅក្នុងជំនាន់សម្តេចព្រះនរោត្តមសីហនុ ពេលដែលបារាំងធ្វើអាណានិគមមកលើប្រទេសកម្ពុជាយើង ហើយការប្រមូលភូមិជំនាន់នោះមានចំនួនពីរលើក។ លើកទីមួយ ប្រជាជនប្រមូលកម្លាំងគ្នាមកឆ្ការព្រៃខ្វាវ និងរស់នៅផ្តុំគ្នាជាក្រុម ដល់លើកទីពីរប្រជាជនប្រមូលគ្នាទៅរស់នៅតាមចិញ្ចើមផ្លូវ ព្រោះពេលយើងបានឯករាជ្យពីអាណានិគមបារាំង សម្តេចព្រះបាទនរោត្តមសីហនុចាប់ផ្តើមបញ្ជាឱ្យមានការរៀបចំបង្កើតភូមិឡើងវិញ និងរៀបចំឱ្យមានប្រជាជនមករស់នៅតាមដងផ្លូវ ដែលការរៀបចំបែបនេះក្នុងជំនាន់នោះគេហៅថា *ភូមិថ្មីតាមដងផ្លូវ* ដូច្នេះប្រជាជនក៏នាំគ្នារើទៅរស់នៅតាមផ្លូវ។[2]

ក្នុងសម័យខ្មែរក្រហមកំឡុងឆ្នាំ១៩៧៦ជិតចូល១៩៩៧ ស្ថានភាពរបស់ប្រជាជនក្នុងភូមិនេះគឺដូចគ្នាទៅនឹងប្រជាជនក្នុងភូមិផ្សេងៗទៀតដែរ ត្រូវបានពួក ប៉ុល ពត ធ្វើការកាត់ និងបែងចែកឱ្យទៅរស់នៅភូមិផ្សេងៗមួយចំហៀងម្នាក់ រហូតទាល់តែសម័យខ្មែរក្រហមបញ្ចប់ទៅទើបនាំគ្នាមករស់នៅក្នុងភូមិជាធម្មតាដូចដើមវិញ។ ខ្មែរក្រហមចូលមកគ្រប់គ្រងភូមិព្រៃខ្វាវតាំងពីឆ្នាំ១៩៧២ឬ១៩៧៣មកម្ល៉េះ ហើយសម័យនោះប្រជាជននាំគ្នាទៅរស់នៅសហករណ៍ និងកៀរប្រមូលឱ្យទៅរស់នៅភូមិផ្សេងៗខ្លះដោយបង្ខំឱ្យធ្វើការដូចជាសន្ទូងដី ជីកប្រឡាយ ហើយមានការវាយធ្វើបាបដល់ប្រជាជនយើងច្រើនដែរ។

ក្នុងឆ្នាំ១៩៨៦ ភូមិនេះនៅមានការប្រទាញប្រទង់ជាមួយខ្មែរក្រហមខ្លះៗដែរ។ លុះដល់ឆ្នាំ១៩៩៣ ពេលធ្វើសមាហរណកម្មពួកខ្មែរក្រហមចូលមកក្នុងរួច ភូមិនេះក៏រំដោះបានទាំងស្រុង លែងមានការប្រទាញប្រទង់ជាមួយខ្មែរក្រហម លែងមានការវាយធ្លាក់ទៀត និងមានសន្តិភាពពេញលេញ។

### ១.២- ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងភូមិ

នៅក្នុងភូមិព្រៃខ្វាវទាំងមូល មានផ្លូវលំតូចៗជាច្រើនខ្សែសម្រាប់ឱ្យប្រជាជនធ្វើដំណើរទៅកាន់លំនៅដ្ឋាន និងទីកន្លែងផ្សេងៗទៀតនៅក្នុងភូមិ ហើយក៏មានផ្លូវសម្រាប់ធ្វើដំណើរទៅកាន់ភូមិដទៃដែលមានព្រំប្រទល់ជាប់គ្នាដែរ។ ផ្លូវទាំងនោះ កាលពីមុនជាផ្លូវដែលអាចធ្វើដំណើរបានដោយថ្មើរជើងប៉ុណ្ណោះ តែបច្ចុប្បន្នផ្លូវភាគច្រើនចាក់ដីក្រួសក្រហម និងអាចធ្វើដំណើរដោយរថយន្តបាន។

ចំពោះវិស័យសុខាភិបាលវិញ ភូមិព្រៃខ្វាវ ពុំមានមណ្ឌលសុខភាពនោះទេ។ ប្រជាជនដែលរស់នៅក្នុងភូមិពេលមានជំងឺតម្កាត់ឬមានស្ត្រីឆ្លងទន្លេ គឺគេត្រូវធ្វើដំណើរទៅពិនិត្យនៅមណ្ឌលសុខភាពក្នុងភូមិព្រៃតាឡី។

កាលពីដើម ស្ត្រីក្នុងភូមិពេលមានផ្ទៃពោះពេលឆ្លងទន្លេ គឺរកយាយម៉បមកបង្កើតនៅផ្ទះ ហើយពេលបង្កើតរួចព្រមទាំងបានសុខសប្បាយទាំងម្តាយនិងកូន គេក៏រៀបទ្រនឹបឱ្យធ្មប មានដូចជាស្រូវ លុយ ឬនំចំណីផ្សេងៗ។ ស្ត្រីដែលឆ្លងទន្លេនោះ ត្រូវនៅលើគ្រែអាំងភ្លើងចន្លោះពី១អាទិត្យទៅ១ខែ ទើបធ្វើពិធីទម្លាក់ចង្ក្រាន តែត្រូវផឹកស្រាថ្នាំដែលចាស់ៗត្រាំទុកឱ្យរាប់ខែមកហើយ និងមិនត្រូវធ្វើការធ្ងន់ទេ ដើម្បីបង្ការនូវជំងឺទាស់ព្រុំរ៉ៃផ្សេងៗ។ លុះដល់សម័យឥឡូវលែងមានស្ត្រីសម្រាលកូននៅផ្ទះទៀតហើយ ហើយក៏មិនអាំងភ្លើងឬធ្វើពិធីទម្លាក់ចង្ក្រានទៀតដែរ គឺគេងាកមកប្រើថ្នាំពេទ្យជំនួសវិញ។ មូលហេតុដែលគេឈប់ប្រើធ្មប ឬរបៀបបុរាណដោយសារប្រជាជនមានការយល់ដឹងច្រើនពីបញ្ហាសុខ

[2] ប្រាក់ ណន មេភូមិក្នុងភូមិព្រៃខ្វាវ(សម្ភាសន៍ ថ្ងៃ១៥ សីហា ២០១៦)

ភាព ព្រោះមានការចុះមកផ្សព្វផ្សាយពីផលវិបាក និងគ្រោះថ្នាក់ផ្សេងៗចំពោះជីវិតនៃការប្រើឆ្មបបុរាណពីសំណាក់ក្រុមគ្រូពេទ្យជំនាញផ្សេងៗរបស់ស្រុក និងខេត្ត។ ជាគោលការណ៍ ការទៅពិនិត្យសុខភាពនៅមណ្ឌលសុខភាពគឺត្រូវចំណាយថវិកាដែរ ប៉ុន្តែតិចតួចប៉ុណ្ណោះសម្រាប់ថ្លៃសេវា និងថ្លៃថ្នាំពេទ្យទៅតាមប្រភេទនៃជំងឺ។ ចំណែកសាលារៀននិងវត្តអារាមវិញ គឺពុំមាននោះទេនៅក្នុងភូមិព្រៃខ្វាវ។ ក្មេងក្នុងភូមិនាំគ្នាទៅរៀននៅសាលាក្នុងវត្តមង្គលមានលក្ខណ៍។ រីឯចាស់ៗបើចង់ទៅវត្តធ្វើបុណ្យទាន គឺត្រូវទៅវត្តនៅក្នុងភូមិផ្សេង តែភាគច្រើនគឺគាត់នាំគ្នាទៅវត្តមង្គលមានលក្ខណ៍។

### ១.៣- មុខរបរចិញ្ចឹមជីវិតរបស់ប្រជាជន

ប្រជានជនភាគច្រើន គឺប្រកបរបរធ្វើស្រែ ចិញ្ចឹមសត្វមាន ដូចជា មាន់ ទា ក្ងាន ជ្រូក គោក្របី និងដាំដំណាំ ដូចជា អំពៅ សណ្តែក ពោត ត្រសក់ ឪឡឹក ខ្ទាយ ល្ពៅ ដូង ស្លឹកបាស ននោងត្រឡាចជាដើម ប៉ុន្តែតិចតួចប៉ុណ្ណោះ មិនមានលក្ខណៈជាចម្ការទេ។ សត្វនិងបន្លែដែលសល់ពីហូបប្រចាំថ្ងៃ ទើបពួកគាត់យកទៅលក់នៅផ្សារ។ ចំពោះគ្រួសារខ្លះ គឺមានកូនចៅទៅធ្វើការរោងចក្រនៅភ្នំពេញ(ភាគតិច) និងនៅទីរួមខេត្ត(ច្រើន) ហើយអ្នកទៅធ្វើការរោងចក្រភាគច្រើនជាមនុស្សស្រីមានវ័យចាប់ពី១៨ដល់៣០ឆ្នាំ ឯមនុស្សប្រុសពុំសូវមានអ្នកទៅធ្វើការរោងចក្រទេ ព្រោះគេមិនយក។ ទន្ទឹមនឹងនោះ ក៏មានប្រជាជនក្នុងភូមិទៅធ្វើការនៅថៃ១នាក់ ជាមនុសប្រុស និងមានគ្រួសារដែលមួយមានកូនស្រីរៀបការទៅនៅប្រទេសកូរ៉េផងដែរ។

កាលពីសម័យមុន ចាស់ៗនៅក្នុងភូមិមានដាំដំណាំ ដូចជា ម្លូរ ស្លែ ត្រកួន និងដំណាំខ្លះទៀតសម្រាប់ផ្គត់ផ្គង់ការហូបចុកក្នុងគ្រួសារ ហើយពេលសល់ពីការហូបចុកទើបយកទៅលក់នៅផ្សារ។ ការដាំដំណាំ គឺគេត្រូវជីកស្រះឬត្រពាំងជាលក្ខណៈគ្រួសារដើម្បីយកទឹកទុកបើប្រាស់ និងស្រោចដំណាំ។ ប្រសិនបើផ្ទះគ្មានស្រះឬត្រពាំងទេ គេអាចមកសុំម្ចាស់ផ្ទះដែលមានស្រះឬត្រពាំងនោះដងទឹកយកទៅប្រើបានគឺម្ចាស់ផ្ទះមិនចិត្តអាក្រក់នោះទេ។ ទាំងនេះ គឺបង្ហាញពីវប្បធម៌នៃការចែករំលែក ជួយគ្នាទៅវិញទៅមករបស់ប្រជាជនខ្មែរយើងដែលមានតាំងតែពីដើមរៀងមក។



អ៊ុំស្រី **កែ សាម៉ុន** កំពុងដកខ្ទាយលក់



ដំណាំអំពៅដែលអ្នកភូមិព្រៃខ្វាវដាំជុំវិញផ្ទះ

ប៉ុន្តែការចិញ្ចឹមសត្វ និងដាំដំណាំ គ្រាន់តែជាមុខរបរបន្ទាប់បន្សំរបស់ប្រជាជនប៉ុណ្ណោះ។ មុខរបរដែលសំខាន់បំផុតរបស់ប្រជាជន គឺការធ្វើស្រែ។ គ្រួសារខ្លះពេលផុតពីរដូវធ្វើស្រែ គេយកដីស្រែ

នោះទៅដាំដំណាំផ្សេងៗដូចជាសណ្តែកបាយ ត្រសក់ ឪឡឹក និងពោតជាដើមគ្រាន់ទុកហូបប្រចាំថ្ងៃ ហើយមានគ្រួសារចំនួន២ឬ៣ ដែលមានជីវភាពធូរធារ គេទិញម៉ាស៊ីនស្រូវ និងគោយន្តដើម្បីទុកជួលឱ្យប្រជាជនក្នុងភូមិ។



ម៉ាស៊ីនកិនស្រូវរបស់ប្រជាជន



គោយន្តដឹកស្រូវ

មូលហេតុដែលប្រជាជនក្នុងភូមិនេះ មិនប្រកាន់យកមុខរបរធ្វើចម្ការជាមុខរបរចម្បងដូចភូមិមួយចំនួនទៀត គឺដោយសារដីនៅតំបន់នេះមានលក្ខណៈទំនាប ពេលរដូវវស្សាងាយនឹងទឹកជន់លិចណាស់ ដូច្នេះមានការពិបាកក្នុងការដាំដំណាំ រីឯរដូវប្រាំងវិញ ពិបាកក្នុងការរកទឹកមកស្រោចដំណាំព្រោះក្នុងភូមិនេះគ្មានប្រឡាយ ឬត្រពាំងទេមេណាមួយសម្រាប់ឱ្យប្រជាជនយកទឹកទុកស្រោចឡើយ គឺមានតែស្រះនិងត្រពាំងតូចៗ។ កាធ្វើស្រែ នៅពេលខ្វះទឹកធ្វើស្រែដោយគ្មានភ្លៀងធ្លាក់គ្រប់គ្រាន់ គឺអ្នកភូមិនាំគ្នាប៉ូមទឹកស្រះឬត្រពាំងនោះដាក់ចូលស្រែ។

កាលមុនឆ្នាំ២០០០ មានប្រជាជនខ្លះប្រកបរបរឡើងត្នោត តែក្រោយមកមិនមានទៀតទេ ដោយសារគេចេះតែមានអារម្មណ៍ខ្លាចធ្លាក់ ព្រមទាំងគិតដល់សុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ។ ជាមួយគ្នានេះក៏មានផ្ទះខ្លះមានមុខរបរទទួលកិនស្រូវដើម្បីរកចំណូលបន្ថែមផងដែរ។

ចំពោះការការធ្វើសិប្បកម្មនៅក្នុងភូមិបច្ចុប្បន្នពុំមានទេ។ បើពីមុនអ្នកស្រុកចាស់ៗខ្លះ គេចេះធ្វើកញ្ច្រែង កន្ទេល ចង្អេ ល្អីទុកប្រើនិងលក់ ដល់ពួកគាត់ស្លាប់អស់លែងមានអ្នកធ្វើទៀតហើយព្រោះក្មេងជំនាន់ក្រោយគ្មានអ្នកចេះដោយគេមិនយកចិត្តទុកដាក់រៀនវិជ្ជានេះតែម្តង។ កាលពីជំនាន់មុនចាស់ៗនៅក្នុងភូមិធ្វើរបស់ទាំងនោះទុកលក់ ហើយលក់ដាច់រហូតដល់ពេលខ្លះធ្វើមិនទាន់ផង ប៉ុន្តែសព្វថ្ងៃអ្នកភូមិនាំគ្នាទិញរបស់ទាំងនោះពីផ្សារមកទាំងអស់។ ចំណែកឧបករណ៍ភ្លេងក៏ដូចគ្នាដែរលែងមានអ្នកធ្វើនិងអ្នកចេះលេងទៀតហើយ។ ដូច្នេះយើងឃើញថា ប្រជាជនក្នុងភូមិព្រៃខ្វាវមានមុខរបរចិញ្ចឹមជីវិតជាសំខាន់ គឺធ្វើស្រែនិងមានដាំដំណាំខ្លះៗ ដើម្បីជួយដល់ការរស់នៅប្រចាំថ្ងៃ ហើយការដាំដំណាំនោះទៀតសោត គឺមានលក្ខណៈតូចតាច និងពឹងផ្អែកលើធម្មជាតិទាំងស្រុង ។

## ២- ការប្រតិបត្តិសាសនានៅភូមិព្រៃខ្វាវ

តាមការសិក្សាស្រាវជ្រាវ យើងឃើញថា នៅក្នុងភូមិព្រៃខ្វាវតាំងពីដើមមកប្រជាជនមានការគោរពប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនគ្រប់សម័យកាលទាំងអស់ លើកលែងតែក្នុងសម័យប៉ុលពត ដែលមានការហាមឃាត់មិនឱ្យប្រជាជនគោរពប្រតិបត្តិសាសនាឡើយ។ ទោះជាបែបនេះក្តី មិន

មែនមានន័យថា ជំនឿសាសនាបានលប់បំបាត់ពីក្នុងចិត្តគំនិតរបស់ប្រជាជនខ្មែរនោះទេ ផ្ទុយទៅវិញ ជំនឿទាំងនោះនៅតែរស់រានមានជីវិតក្នុងដួងចិត្ត និងស្មារតីរបស់ប្រជាជនខ្មែរយើងជានិច្ច។ ជាភស្តុតាង គឺគ្រាន់តែសម័យ ប៉ុល ពត ដួលរលំនៅឆ្នាំ១៩៧៩ភ្លាម ថ្នាក់ដឹកនាំផ្តល់សិទ្ធិសេរីភាពឱ្យប្រជាជនគោរពព្រះពុទ្ធសាសនាឡើងវិញ និងបង្ករភាពងាយស្រួលឱ្យប្រជាជនទូទៅបានគោរពក៏ដូចជាប្រតិបត្តិនូវជំនឿសាសនាផ្សេងៗរបស់ខ្លួន ដោយមិនមានការហាមឃាត់ទេ ពោលគឺមានការបើកទូលាយរហូតមក ជាពិសេសជំនឿអរូបីទៅលើអ្នកដូន អ្នកតា និងទួលអង្គដែលសល់ពីសម័យបុរាណ ហើយប្រជាជនខ្មែរស្ទើរគ្រប់ទីកន្លែងនាំគ្នាគោរព និងជឿតាំងពីសម័យដើមមក។

### ២.១- ការប្រតិបត្តព្រះពុទ្ធសាសនា

ថ្វីត្បិតតែនៅក្នុងភូមិព្រៃខ្វាវពុំមានវត្តអារាម ប៉ុន្តែប្រជាជនភូមិនេះភាគច្រើនគោរពប្រតិបត្តិសាសនាព្រះពុទ្ធយ៉ាងខ្លាំងដែលយើងអាចមើលឃើញតាមរយៈការសុំសីលនៅវត្តអរាមឬនៅផ្ទះ និងពិធីបុណ្យផ្សេងៗ។[3]

- **ការសុំសីល** ជារៀងរាល់ថ្ងៃសីល ចាស់ៗក្នុងភូមិតែងតែនាំគ្នាទៅសុំសីលនៅវត្តអារាមហើយមានរៀបចំចង្ហាន់យកទៅប្រគេនព្រះសង្ឃផងដែរ ដោយអ្នកខ្លះទៅពេលព្រឹកព្រលឹម ឯអ្នកខ្លះទៀតទៅពេលថ្ងៃត្រង់ និងមានអ្នកខ្លះទៅតាំងពីព្រឹករហូតដល់ថ្ងៃត្រង់តែម្តង។ ចំពោះអ្នកភូមិវ័យក្មេងខ្លះដែលមិនទាន់បានសុំសីល ជារឿយៗគេតែងតែយកចង្ហាន់ទៅប្រគេនព្រះសង្ឃក្នុងថ្ងៃសីលដែរ ហើយជួនកាលពួកគេនៅញ៉ាំអាហារថ្ងៃត្រង់នៅវត្ត ជជែកលេងជាមួយចាស់ៗ និងព្រះសង្ឃ ដើម្បីចែករំលែកនូវកិច្ចការផ្សេងទាក់ទងការរស់នៅ ការធ្វើស្រែចម្ការ និងបញ្ហាផ្សេងៗជាដើម។

ក្រៅពីការសុំសីលនៅវត្ត ជារៀងរាល់ឆ្នាំ ប្រជាជនក្នុងភូមិតែងមានរៀបចំបុណ្យផ្កាឬបុណ្យកឋិនដង្ហែរទៅវត្តផ្សេងៗ ដើម្បីប្រមូលបច្ច័យយកទៅកសាងវត្តអារាម និងរចនាសម្ព័ន្ធផ្សេងៗទៀតក្នុងវត្ត។ ការធ្វើបុណ្យកឋិន ឬបុណ្យផ្កានេះ អ្នកផ្តើមបុណ្យបានអញ្ជើញប្រជាជននៅក្នុងភូមិ និងក្រៅភូមិឱ្យចូលរួមជាមួយ ហើយការចូលបច្ច័យបុណ្យ គឺទៅតាមទឹកចិត្តសទ្ធាមិនមានការកំណត់នោះទេ។

- **ពិធីបុណ្យសព** នៅក្នុងភូមិប្រសិនបើមានអ្នកភូមិណាម្នាក់ស្លាប់ គឺក្រុមគ្រួសារមានការរៀបចំពិធីបុណ្យទៅតាមទំនៀមទម្លាប់ប្រពៃណីរបស់ព្រះពុទ្ធសាសនា ដោយមាននិមន្តព្រះសង្ឃពីវត្តផ្សេងៗមកសូត្រមន្ត ឬបង្សុកូលឧទ្ទិសជុនដល់សពដែលបានចែកឋានទៅ។ ចំពោះសាកសព គឺប្រជាជនក្នុងភូមិព្រៃខ្វាវគេនិយមដុត ឬបូជាក្នុងម៉េន ហើយគេមិនចូលចិត្តបញ្ចុះសពទេ។

ក្រោយពីរៀបចំពិធីបុណ្យបបូជាសពរួច រយៈពេល៧ថ្ងៃបន្ទាប់មក គឺមានរៀបចំពិធីបុណ្យគំរប់៧ថ្ងៃ និងបុណ្យគំរប់១០០ថ្ងៃ។ ប៉ុន្តែមានគ្រួសារខ្លះគេរៀបចំបុណ្យ៧ថ្ងៃនិងបុណ្យ១០០ថ្ងៃជាមួយគ្នាតែម្តង ដោយសារគ្នាមានជីវភាពខ្វះខាត មិនសូវសម្បូរធនធាន ឬប្រាក់កាស។ ជាមួយគ្នានេះដែរពេលមានអ្នកភូមិណាម្នាក់ស្លាប់ មេភូមិដើរប្រកាសប្រាប់ដំណឹងដល់ប្រជាជនក្នុងភូមិដើម្បីប្រមូលលុយសង្គហៈយកទៅជូនគ្រួសារសព ហើយក្រៅពីនេះក៏មានប្រាក់ឧបត្ថម្ភពីសមាគមក្នុងវត្តផងដែរ។

បើតាមអ៊ំស្រី **កែ សាម៉ុន**[4] បានប្រាប់ថា*សមាគមក្នុងវត្តគឺចូលលុយមួយឆ្នាំ១៤០០០រៀល*

---

[3] **ឡាយ ពាប់** អាយុ៧៥ឆ្នាំ រស់នៅភូមិព្រៃខ្វាវ(បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)

[4] **កែ សាម៉ុន** អាយុ៧០ រស់នៅភូមិព្រៃខ្វាវ(បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)

*តែបើគ្រួសារណាអត់មានក៏អត់ទៅ ចំណែកគ្រួសារខ្លះទៀតបើម្ដាយគេស្លាប់ទៅ ហើយកូនចង់បង់បន្ត ទៀតក៏បាន។ ការជួយរបស់អ្នកភូមិ គឺគេជួយទៅតាមទឹកចិត្តដែរ មានដូចជា បច្ច័យ អង្ករ សម្ភារៈផ្សេងៗតាមលទ្ធភាព។* អ៊ំស្រីក៏បានបញ្ជាក់ទៀតថា *កាលពីមុនឆ្នាំ២០០៦ ពេលមានមនុស្សស្លាប់ មានអ្នកភូមិខ្លះជួយរកឈើមកធ្វើជាមឈូស ជួយដាំស្ល និងជួយកិច្ចការផ្សេងទៀត។ ដល់ឥឡូវមឈូសគេលែងធ្វើ គេនាំគ្នាទិញវិញ តែការជួយផ្សេងៗគឺនៅតែមានជួយរហូតដល់បុណ្យសពចប់។* ក្នុងពិធីបុណ្យទាំងបុណ្យសព និងបុណ្យ៧ថ្ងៃគឺទទួលបច្ច័យដូចគ្នាទោះគ្រួសារចិនឬខ្មែរ។ ប៉ុន្តែនៅភ្នំពេញវិញ មានគ្រួសារចិនខ្លះគេអត់ទទួលបច្ច័យពេលបុណ្យ៧ថ្ងៃទេ ព្រោះគេមិនចង់ឱ្យអ្នកដែលមកចូលរួមពិធីបុណ្យសពនោះចំណាយថវិកាច្រើន។

- **អំពីបុណ្យបាតលាន** ពិធីបុណ្យបាតលាន គឺជាពិធីបុណ្យដែលអ្នកភូមិនិយមធ្វើក្រោយពីរដូវច្រូតកាត់រួច ដើម្បីរលឹកគុណដល់ព្រះធរណី និងព្រះគង្គាដែលបានជួយឱ្យពួកគេធ្វើស្រែបានផលល្អ។ ប្រជាជនភូមិខ្លះ ឬតំបន់ខ្លះ គេមិនហៅបុណ្យបាតលានទេ គឺគេហៅថា បុណ្យដាលានឬបុណ្យបោស





ក្រុមការងារកំពុងសម្ភាសន៍អ៊ំស្រី **កែ សាម៉ុន** ដែលជាចាស់ទុំក្នុងភូមិ

លាន។ ប្រជាជនជនភូមិព្រៃខ្វាវនិយមធ្វើពិធីបុណ្យបាតលាននៅកណ្ដាលភូមិ ប៉ុន្តែពេលខ្លះគេក៏នាំគ្នាទៅធ្វើពិធីនេះនៅកន្លែងអ្នកតាដែរ ដោយគេជួលរោងមកសង់កុំឱ្យក្ដៅដល់ព្រះសង្ឃ និងអ្នកចូលរួម។

ចំពោះកម្មវិធីបុណ្យ គឺច្រើនធ្វើមួយថ្ងៃមួយយប់ ដោយពេលល្ងាចថ្ងៃទីមួយមាននិមន្តមកសូត្រមន្តចម្រើនពរជ័យ។ លុះព្រឹកស្អែកឡើងដែលជាថ្ងៃទី២មាននិមន្តព្រះសង្ឃរាប់បាត ឆាន់ចង្ហាន់ និងបង្សុកូលជាដើម ។ ការចំណាយសម្រាប់ពិធីបុណ្យនេះ គឺបានប្រាក់ពីការប្រមូលរៃអង្គាសពីប្រជាជនក្នុងភូមិនៅពេលដែលមូលមតិគ្នា។ កន្លងមកប្រជាជនភូមិព្រៃខ្វាវធ្វើបុណ្យបាតលានរៀងរាល់ឆ្នាំ ទើបរយៈពេលបីឆ្នាំចុងក្រោយនេះដែលប្រជាជនមិនបានធ្វើ ដោយសារពុំសូវមានទឹកភ្លៀងហើយប្រជាជនប្រមូលផលមិនសូវបាន។

- **ពិធីបុណ្យឡើងសាលា** ប្រជាជនក្នុងភូមិព្រៃខ្វាវតែងតែមានរៀបចំពិធីបុណ្យមួយដែលអាចខុសពីប្រជាជននៅភូមិដទៃខ្លះ ពិធីបុណ្យនោះគេហៅថាបុណ្យឡើងសាលា។ តាមលោកមេភូមិបញ្ជាក់ថា *បុណ្យឡើងសាលាជាបុណ្យដែលព្រះសង្ឃរៀបចំធ្វើដើម្បីឱ្យប្រជាជនដែលមានធាតុរបស់ក្រុមគ្រួសារ ហើយពុំមានលទ្ធភាពធ្វើបុណ្យបានយកធាតុរបស់ក្រុមគ្រួសារ ឬសាច់ញាតិរបស់គេទៅដាក់*

*នៅវត្តបាន។*

អ៊ំស្រី **កែ សាម៉ុន** ក៏បានឱ្យដឹងដែរថា គឺបុណ្យឡើងសាលាពីសម័យដើមខុសពីសម័យឥឡូវ ព្រោះមនុស្សសម័យដើម គឺក្រច្រើន ដូច្នេះគេធ្វើបុណ្យឡើងសាលារៀងរាល់ខែជេស្ឋ ដើម្បីឱ្យគ្រួសារដែលក្រីក្របានយកជាតុទៅដាក់ក្នុងវត្ត ដោយអាចារ្យជាអ្នកផ្តើមគំនិតប្រកាសប្រាប់ពីបុណ្យនោះចំណាយអស់ប៉ុន្មានហើយក៏រៃអង្គាសថវិកាតាមគ្រួសារដែលត្រូវយកជាតុទៅដាក់ និងរៀបខ្ទង់ចំណាយយ៉ាងច្បាស់លាស់។ ដល់ថ្ងៃបុណ្យគេធ្វើពេងនៅវត្តបុណ្យរយៈពេលបីយប់បីថ្ងៃ ដូច្នេះគ្រួសារនីមួយៗគេបែងចែកការកិច្ចគ្នាទៅរៀបចំពិធីរៀងៗខ្លួន គឺគ្រួសារខ្លះដើរទិញសម្ភារៈ គ្រួសារខ្លះទៀតរៀបចំដាំបាយធ្វើម្ហូប គ្រួសារខ្លះធ្វើពេង គ្រួសារខ្លះចាំទទួលព្រះសង្ឃនិងភ្ញៀវ ខ្លះលាងចានឆ្នាំងជាដើម។ តែសម័យឥឡូវអ្នកមានលុយ គឺគេធ្វើដោយខ្លួនគេទៅចំណាយពី៣ទៅ៤លានរៀល ចំពោះគ្រួសារដែលអត់មានលុយ គឺរង់ចាំពេលណាមានគេធ្វើបុណ្យនៅវត្តនឹងអាលយកជាតុទៅដាក់នឹងគេដែរ។

- **ពិធីបុណ្យផ្កា និងបុណ្យកឋិនទាន** ប្រជាជនភូមិព្រៃខ្វាវ តែងតែរួមរួមគ្នាធ្វើបុណ្យកឋិនទាន និងបុណ្យផ្កាជារៀងរាល់ឆ្នាំ ដើម្បីយកបច្ច័យទៅចូលរួមជួយកសាងវិហារ កុដិនៅតាមទីអារាមផ្សេងដោយមិនប្រកាន់ថាភូមិរបស់ខ្លួនមានវត្តឬអត់វត្តនោះទេ។

ទាំងនេះបង្ហាញឱ្យឃើញថា ទោះបីក្នុងភូមិព្រៃខ្វាវទាំងមូលពុំមានវត្តអារាម ប៉ុន្តែប្រជាជនក្នុងភូមិព្រៃខ្វាវក៏មាននៅតែមានការប្រតិបត្តិព្រះពុទ្ធសាសនាយ៉ាងមុតមាំដែរ ទោះជាត្រូវធ្វើដំណើរផ្លូវឆ្ងាយចំណាយកម្លាំងឬថវិកា ក៏ពួកគេមិនរួញរានៅក្នុងការគោរពប្រតិបត្តិព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិដែរ ហើយដែលការគោរពនេះគឺបានផុសចេញពីដួងចិត្តរបស់ពួកគេពិតៗមិនមានការបង្ខិតបង្ខំឡើយ។

## ២.២- ការប្រតិបត្តិគ្រិស្តសាសនានៅភូមិព្រៃខ្វាវ

នៅក្នុងភូមិព្រៃខ្វាវក៏ដូចជាភូមិនានានៅក្នុងឃុំត្រពាំងធំខាងជើងដែរ គឺអាជ្ញាធរដែនដី និងមេភូមិពុំមានការហាមឃាត់ ឬបង្អាក់ប្រជាជននៅការគោរពប្រតិបត្តិសាសនាផ្សេងឡើយ ហើយប្រជាជនក្នុងភូមិព្រៃខ្វាវប្រហែលជាពីរទៅបីឆ្នាំចុងក្រោយនេះមានអ្នកគោរពគ្រិស្តសាសនាចំនួន២ឬ៣គ្រួសារដែរ។ មូលហេតុដែលគ្រួសារទាំងនេះគោរពគ្រិស្តសាសនា។

នៅក្នុងភូមិនេះមិនមានវិហារគ្រិស្តសាសនាទេ គឺមានតែនៅក្នុងភូមិផ្សេង។ ប៉ុន្តែប្រជាជនភូមិព្រៃខ្វាវដែលគោរពគ្រិស្តសាសនាគឺមិនបានទៅវិហារគ្រិស្តនៅភូមិផ្សេងដែរ គឺពួកគេគោរពប្រតិបត្តិតែនៅក្នុងផ្ទះរបស់ខ្លួន ហើយរៀងរាល់៣ទៅ៤ខែមានក្រុមបព្វជិតគ្រិស្តសាសនាគេចុះមកសុំផ្ទះអ្នកដែលគោរពសាសនានោះ ដើម្បីរៀបចំពិធី។ ជាទូទៅ ពេលដែលក្រុមគ្រិស្តសាសនាមកធ្វើពិធី គឺគេតែងតែផ្តល់ដំណឹងនិងសុំការអនុញ្ញាតិពីភូមិជាមុន។

ពិធីរបស់ពួកគេធ្វើឡើងដោយហៅប្រជាជនក្នុងភូមិ ជាពិសេសក្មេងៗក្នុងភូមិណាដែលទំនេរចង់ចូលរួមជាមួយពួកគេទៅជុំគ្នា ហើយគេចែកកាតាប សម្ភារៈសិក្សា ឬនំចំណីជាដើម ប៉ុន្តែជាក់ស្តែងគឺមានតែក្មេងទេដែលទៅចូលរួម។ បន្ទាប់ពីចែករួចគេបង្ហាត់អ្នកដែលចូលរួមសូត្រធម៌ ឬច្រៀងចម្រៀងរបស់ព្រះតាមពួកគេ។ តាមការបញ្ជាក់របស់ពូមេភូមិ **ប្រាក់ ណន** អ្នកដែលទៅចូលរួមគឺមានសុទ្ធតែមនុស្សចាស់លើកលែងតែគ្រួសារដែលគេគោរពសាសនានោះ ដូច្នេះរយៈពេលក្រោយៗមកក្រុម

បព្វជិតបានឱ្យគេហៅតែក្មេងៗទៅចូលរួមវិញ។ មូលហេតុដែលគេហៅតែក្មេងនេះ គឺប្រហែលជាគេគិតថាក្មេងៗគឺងាយស្រួលក្នុងការបណ្តុះ និងបញ្ចូលមនោគមវិជ្ជាសាសនាចំណែកមនុស្សចាស់វិញមានការពិបាក ព្រោះផ្នត់គំនិតពួកគាត់ជក់ជាប់នឹងព្រះពុទ្ធសាសនាជ្រាលជ្រៅទៅហើយ។ តែផ្ទុយទៅវិញតាមការជាក់ស្តែងការដែលក្មេងៗក្នុងភូមិទៅ គឺដើម្បីយកតែសម្ភារៈ ប្រដាប់ក្មេងលេងតែប៉ុណ្ណោះ ព្រោះពួកគេមានទំនោរប្រតិបត្តិព្រះពុទ្ធសាសនាតាមឪពុកម្តាយ និងក្រុមគ្រួសាររួចទៅហើយ។

ដូច្នេះយើងឃើញថា ការប្រតិបត្តិគ្រិស្តសាសនានៅក្នុងភូមិព្រៃខ្វាវគឺពុំមានសកម្មភាពផុលផុសដូចការប្រតិបត្តិព្រះពុទ្ធសាសនាទេ។ គ្រួសារដែលគោរពគ្រិស្តសាសនាពុំបានបង្ហាញពីឆន្ទះមោះមុតជាប្រចាំរបស់ខ្លួនដើម្បីបំពេញកាតព្វកិច្ចជាគ្រិស្តសាសនិក ដែលត្រូវទៅចូលវិហារសូត្រគម្ពីររៀងរាល់ព្រឹកថ្ងៃអាទិត្យឡើយ។ ទន្ទឹមនឹងនោះក្រុមគ្រិស្តសាសនិកទាំងនោះ ក៏ពុំដែលដើរផ្សព្វផ្សាយពីព្រះគម្ពីរទៅដល់ប្រជាជនដទៃទៀតក្នុងភូមិដែរ។ សកម្មភាពនៃការប្រតិបត្តិរបស់ពួកគេគឺមានតែពេលដែលក្រុមបព្វជិតចុះមករៀបចំពិធីតែប៉ុណ្ណោះ ក្រៅពីនោះពួកគេមាសកម្មភាពចូលរួមពិធីផ្សេងៗជាមួយប្រជាជនក្នុងភូមិជាធម្មតា គ្រាន់តែមិនសំពះព្រះសង្ឃតែប៉ុណ្ណោះ។ ជាងនេះទៅទៀត ពួកគេមិនដែលមានបញ្ហាអ្វីជាមួយប្រជាជនក្នុងភូមិឡើយ គេនៅតែរាប់អានគោរពស្រឡាញ់គ្នាជាធម្មតា។

## ៣- ជំនឿអ្នកតារបស់ប្រជាជននៃភូមិព្រៃខ្វាវ

ក្នុងភូមិព្រៃខ្វាវពីមុនមកប្រជាជនមានជំនឿលើអ្នកតាច្រើន ពីព្រោះនៅក្នុងភូមិនេះគេឃើញមានរោងអ្នកតាច្រើន ដូចជាអ្នកតាសុខ អ្នកតាអេង ទួលអង្គព្រៃទន្លាប់ ត្រពាំងតាពែក និងអ្នកតាផ្សេងទៀត។ ប៉ុន្តែមកដល់បច្ចុប្បន្នអ្នកតាដែលប្រជាជនភូមិព្រៃខ្វាវនៅតែមានជំនឿគឺអ្នកតាសុខ អ្នកតាត្រពាំងតាពែក និងទួលអង្គព្រៃទន្លាប់។

### ក- អ្នកតាសុខ

អ្នកតាសុខមានទីតាំងស្ថិតនៅកណ្តាលវាលស្រែ ហើយនៅក្បែររោងអ្នកតានោះ គឺមានដើមត្រយឹងយ៉ាងធំមួយដែលផ្លែរបស់វាពណ៌ខៀវ មានរូបរាងដូចផ្លែមង្ឃុត ហើយគេអាចញាំបានព្រោះវាមានរសជាតិផ្អែម។

អំពីប្រវត្តិអ្នកតានេះកើតឡើងដូចម្តេច ពុំមានប្រជាជនក្នុងភូមិណាម្នាក់ដឹងច្បាស់នោះទេ គ្រាន់តែដឹង និងលឺការតំណាលតៗគ្នាថា អ្នកតាសុខនេះមានតាំងពីយូរយារណាស់មកហើយ ពោលគឺកើតមកឃើញតែម្តង ហើយក៏មិនដឹងកើតមានតាំងពីជំនាន់ណាមក ហើយកាលពីជំនាន់ឪពុកម្តាយរបស់គាត់ក៏ឃើញនៅទីនេះដែរ។

តាមប្រសាសន៍លោកមេភូមិថា មូលហេតុដែលគេគោរពអ្នកតានេះ ដោយសារគេមានជំនឿតគ្នាៗមក ប៉ុន្តែជំនឿនេះត្រូវបានបាត់បង់ទាំងស្រុងនៅក្នុងសម័យ ប៉ុល ពត។ លុះក្រោយពេលសម័យប៉ុល ពត ដួលរលំជំនឿរបស់អ្នកស្រុកទៅលើអ្នកតាសុខនេះក៏កើតមានឡើងវិញ និងបានបញ្ចេញរិទ្ធិនិងធ្វើឱ្យប្រជាជនបានឃើញ។

អ៊ំប្រុស **អម អូន** ថា កាលនោះមានយាយម្នាក់ពេលបែកសម័យ ប៉ុល ពត មកវិញគាត់មានជីវភាពខ្វះខាតពេក អត់មានអីហូប គាត់ក៏ដើរខ្វាកង្កែបនៅទ្នេងដំបូក ក្រោមដើមត្រយឹងនោះ ហើយពេលទៅដល់ផ្ទះវិញក៏ស្រាប់តែឈឺប្រកាច់ភ្លាមនោះបងប្អូនកូនចៅក៏នាំគ្នាត់មករកអ៊ំ និងអ្នកភូមិឱ្យទៅ

ជួយ។ ពេលអ៊ំនិងប្រពន្ធព្រមទាំងអ្នកភូមិទៅដល់ស្រាប់តែមានរូប និងសំឡេងយាយម្នាក់ចូលមកសណ្ឋិតក្នុងខ្លួនរបស់គាត់ ហើយស្រែកប្រាប់ថា *គេនៅសុខៗស្រាប់តែយកកង្វែរមកកាយរុករានកន្លែងគេនៅ ដូច្នេះតាឯងត្រូវធ្វើជាប្រធានមើលការខុសត្រូវ ថែទាំកន្លែងដំបូកនេះកុំឱ្យគេមកអាចមកនោម កាប់ព្រៃ ឬជីកកូរកកាយកន្លែងនេះទៀត។* ពេលនោះគាត់ក៏និយាយតបថា *អត់អីទេចាំខ្ញុំមើលថែកន្លែងឱ្យ ឥឡូវនេះបើកូនចៅមានធ្វើអីខុសកុំប្រកែប្រកាន់អី*។ ក្រោយមកយាយម្នាក់នោះក៏ជាពីជំងឺទៅ។[5]

ចាប់តាំងពីពេលនោះមកប្រជាជនក្នុងភូមិក៏មានជំនឿលើអ្នកតា ហើយក៏នាំគ្នាមកគោរពបន់ស្រន់រហូរមក ដោយរៀបចំឱ្យមានខ្ទមអ្នកតាធ្វើពីឈើតូចមួយ ព្រោះពីមុនមកកន្លែងអ្នកតានេះពុំមានរោងអីទេ គឺមានតែដើមឈើ ដំបូក និង ដុំថ្ម ដែលគេដាក់ចំណាំ។ លុះដល់ឆ្នាំ២០១១ មានគ្រួសារមួយរស់នៅភ្នំពេញគេបានមកសង់រោងអ្នកតាជាថ្មព្រមទាំងចាក់សាបខឿនជុំវិញ។ ក្រុមគ្រួសារនោះមានជំនឿលើអ្នកតានេះណាស់ ព្រោះគេបន់ស្រន់សុំអ្វីទៅគឺតែងតែបានដូចបំណង ដូច្នេះគេតែងតែមកសែនពេលមានរដូវបុណ្យទានផ្សេងៗ។



អ៊ំប្រុស **អម អូន** និងអ៊ំស្រី **កែ សាម៉ុន**
កំពុងផ្តល់បទសម្ភាសន៍ដល់ក្រុមការងារ

ក្រៅពីក្រុមគ្រួសារខាងលើ ប្រជាជនក្នុងភូមិមួយចំនួនដែលជឿលើអបិយជំនឿ ក៏តែងតែនាំគ្នាមកបន់ស្រន់អ្នកតាសុខនេះដែរ។ ភាគច្រើនគេមកបន់សុំឱ្យជានៅពេលមានជំងឺអ្វីមួយ ឬឈឺមិនដឹងមូលហេតុ មើលរបស់ដែលបាត់សុំរកឱ្យឃើញ និងសុំលេខឆ្នោតជាដើម។

លោកមេភូមិក៏បានឱ្យដឹងផងដែរថា អ្នកដែលបន់អ្នកតានៅទីនេះភាគច្រើនជាមនុស្សប្រុសដែលមានវ័យចាប់ពីអាយុ៥០ឆ្នាំឡើង។ ចំណែកមនុស្សស្រីភាគច្រើនគឺជាអ្នកមកលាបំណន់ឱ្យប្ដី ព្រោះពេលបន់គឺគេអុជធូបនិយាយបន់ស្រន់នៅផ្ទះពុំមករោងអ្នកតាផ្ទាល់ទេ ដល់ពេលគេបានដូចបំណងហើយដល់រដូវសែនដូចជាចូលឆ្នាំ ឆេងម៉េងទើបគេយករបស់របរមកសែនថ្វាយដល់អ្នកតាដែលមានដង្វាយដូចជាស្រា បារី មាន់ស្ងោរ ក្បាលជ្រូកស្ងោរ ចេក ផ្លែឈើជាដើម។ មានអ្នកភូមិខ្លះលេងកន្ទុយលេខ ក៏គេឧស្សាហ៍មកបន់នៅទីនេះដែរ ហើយបានត្រូវរង្វាន់៣លេខគេក៏យកមាន់ស្ងោរមកសែនថ្វាយដល់អ្នកតា ។

របៀបនៃការបន់ ដំបូងឡើយអ្នកដែលបន់នៅពេលមានបញ្ហាអ្វីមួយ គឺគេទៅរកគ្រូទាយឱ្យមើល បើគ្រូទាយមើលឃើញថា អ្នកនោះមានខុសទាស់អ្វីជាមួយអ្នកតាសុខនេះហើយក៏ប្រាប់ឱ្យនិយាយបន់ស្រន់សុំអ្នកតាដោយសន្យាថ្វាយនេះ ថ្វាយនោះតាមគ្រូមើលឃើញប្រាប់ លុះពេលបានដូច

[5] **អម អូន** អាយុ៧៥ឆ្នាំ ជាចាស់ទុំក្នុងភូមិព្រៃខ្វាវ(បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)

បំណាងហើយទើបរៀបចំរបស់ទាំងនោះទៅសែនលាមាត់ទៅ។ ក្នុងករណីទៅបន់សុំឱ្យអ្នកជំងឺជា គឺគេឱ្យអ្នកជាទៅរកគ្រូមើល តែបើបាត់របស់ឬសុំលាភសក្ការៈផ្សេងៗគឺអ្នកនោះត្រូវទៅផ្ទាល់។

ចំពោះទ្រនឹបដែលត្រូវរៀបពេលសែន គឺអាចមានការខុសគ្នាទៅតាមអ្នកមកមកបន់ ប៉ុន្តែជាទូទៅមានដូចជាមាន់ស្ងោរ ក្បាលជ្រូកស្ងោរ ចេក ស្លាធ័រដូង ទៀន ធូប បាយស បាយក្រហម ចេក ផ្លែឈើផ្សេងៗ និងអ្នកខ្លះតម្រូវឱ្យសែនពែរពារ៉ូត(ពែរដែលគេកាច់ឱ្យទៅជាបីជាន់ឬបីថ្នាក់)។ ក្នុងករណីបន់សុំឱ្យអ្នកជំងឺជា គឺហាមអ្នកជំងឺដាច់ខាតមិនឱ្យញ៉ាំរបស់ដែលគ្រូប្រាប់ឱ្យយកទៅសែនទេទោះបីអ្នកជំងឺឃ្លានរបស់នោះយ៉ាងណាក៏ដោយ គឺចាំទាល់តែអ្នកជំងឺជាហើយទៅសែនលាមាត់រួចទើបអាចទៅទិញរបស់នោះយកមកញ៉ាំបាន។ ឧទាហរណ៍ អ្នកជំងឺម្នាក់ឈឺទៅរកគ្រូខ្មែរ ហើយគ្រូខ្មែរឱ្យយកចេកទៅបន់អ្នកតានោះ ដូច្នេះមុនពេលទៅសែនបន់ស្រន់អ្នកជំងឺនោះហាមដាច់ខាតមិនឱ្យញ៉ាំចេកទេ គឺទាល់តែសែនអស់ធូបហើយទើបអាចញ៉ាំបាន។

អ៊ំប្រុស **អម អូន** ក៏បានបញ្ជាក់ថែមថា អ្នកដែលជឿ និងមកបន់នៅទីនេះ គឺមានគ្រប់វ័យទាំងស្រីទាំងប្រុស មិនមែនត្រឹមតែប្រជាជនក្នុងភូមិប៉ុណ្ណោះទេ គឺមានអ្នកមកពីភ្នំពេញផងដែរឱ្យតែមានកិច្ចការ ឬឈឺអីគេមកបន់ហើយគេហៅថាអ្នកតានេះថា *អ្នកតាម្ចាស់ស្រុក*។ ជាក់ស្តែងពីមុនមានអ្នកភ្នំពេញម្នាក់ឈឺមើលមិនជាទៅដេកពេទ្យជាង១ខែក៏ទៅរកគ្រូខ្មែរឱ្យទាយមើល ហើយគ្រូនោះក៏ប្រាប់ថាអ្នកតានេះធ្វើ ដូច្នេះឱ្យមកបន់ ពេលបន់ហើយក៏ជាទៅ។

ការសែនលាមាត់បំណន់នេះ គឺគេសែនដាក់ទៅតាមទិសទៀត គឺតាមការបញ្ជាក់ប្រាប់ពីគ្រូទាយដែលបានមើលឱ្យមិនមែនចេះយកទៅដាក់ក្នុងរោងអ្នកតាតាមចិត្តឡើយ គឺជួនកាលគ្រូតម្រូវឱ្យសែនដាក់ក្រៅរោង និងដាក់តាមទិសដែលគេត្រូវសែន តែក៏មានអ្នកភូមិខ្លះគេបានមកអុជធូបបន់ផ្ទាល់នៅទីនេះដែរ។ អ្នកដែលមកបន់គេមិនដែលយកសំណែនទៅវិញទេ គឺមានតែក្មេងៗក្នុងភូមិជាអ្នកចាំយក។

ផ្ទុយទៅវិញមានអ្នកខ្លះ ពេលឈឺគេបានមកបន់នៅអ្នកតានេះតែអត់ជានោះទេ ដូច្នេះគេក៏គ្មានជំនឿជាមួយអ្នកតានេះដែរ ព្រោះមិនមែនអ្នកតានេះជាអ្នកធ្វើឱ្យគេឈឺទេ។ ការដែលគេដឹងថាមិនមែនអ្នកតានេះដែលធ្វើឱ្យគេឈឺ ព្រោះបើអ្នកតានេះធ្វើឱ្យគេឈឺមែនពេលបន់ទៅប្រាកដជាជាហើយ ដូច្នេះមានតែអ្នកតាផ្សេង។

ដូច្នេះយើងឃើញថា អ្នកតាសុខ ឬអ្នកតាម្ចាស់ស្រុកតាំងពីមុនរហូតដល់បច្ចុប្បន្ន គឺនៅតែមានឥទ្ធិពល និងអត្ថិភាពនៅក្នុងផ្នត់គំនិតប្រជាជនភូមិព្រៃខ្វាវ និងប្រជាជនភូមិផ្សេងមួយចំនួនទៀត ព្រោះប្រជាជននៅតែមកបន់ស្រន់ និងសែនដល់អ្នកតាម្ចាស់ស្រុកដូចយើងឃើញស្រាប់ពេលមានការរៀបអាពាហ៍ពិពាហ៍ អាចារ្យយកកូនក្រមុំកូនកម្លោះ ឱ្យរៀបចំពិធីសែនប៉្តឹងអ្នកតាម្ចាស់ស្រុកថាមានជនចំណូលថ្មីមករស់នៅក្នុងភូមិនេះ ការសែនប្តឹងនេះគឺធ្វើនៅក្នុងភូមិលំនៅដ្ឋានដោយមិនយកទៅសែននៅរោងអ្នកតានោះទេ។ ពិធីសែនប្តឹងអ្នកតានេះ មានតាំងពីបរមបុរាណមកម្ល៉េះ គ្រាន់តែជំនឿនេះបើប្រៀបសម័យមុនមកដល់សម័យបច្ចុប្បន្នមានការថយចុះច្រើនជាងមុន ដោយសារសម័យបច្ចុប្បន្នក្មេងៗជំនាន់ក្រោយគេពុំសូវមានជំនឿលើកម្លាំងក្រៅខ្លួនឡើយ គេច្រើនជឿទៅលើវិទ្យាសាស្ត្រពិតច្រើនជាង ពីព្រោះវិទ្យាសាស្ត្រមានការពន្យល់បកស្រាយច្បាស់លាស់មិនដូចជំនឿតាមបែបអរូបីឡើយ។

ប៉ុន្តែទោះបីយ៉ាងណាទំនៀមទម្លាប់ក្នុងការសែនឧទ្ទិសជូនសាច់ញាតិដែលចែកឋាននៅមានអត្ថិភាពចំពោះពួកគេនៅឡើយ ជាក់ស្តែងដូចជារឿងរ៉ាវដែលទាក់ទងនឹងអង្គព្រៃទន្លាប់ខាងក្រោមនេះស្រាប់។

### ខ- អង្គព្រៃទន្លាប់

អង្គព្រៃទន្លាប់ គឺជាឈ្មោះរបស់ទួលអង្គបុរាណមួយដែលស្ថិតនៅក្នុងភូមិព្រៃខ្វាវ។ មូលហេតុដែលគេហៅកន្លែងនោះថា អង្គព្រៃទន្លាប់ ដោយសារទីនោះមានដើមទន្លាប់មួយយ៉ាងធំ និងមានព្រៃឈើតូចៗដុះជុំវិញ។ អ្នកភូមិព្រៃខ្វាវមានជំនឿថា អង្គនេះគឺជាទីតាំងបញ្ចុះសពរបស់មនុស្សជំនាន់ដើម។ ការជឿបែបនេះដោយសារមានតឹកតាងបែបបុរាណវិទ្យាបន្សល់ទុកហូតដល់ពេលបច្ចុប្បន្ន ដូចជាថ្មចម្លាក់ជាដើម។



អ៊ំប្រុស **លី ខែម** កំពុងផ្តល់បទសម្ភាសន៍អំពីទួលអង្គព្រៃទន្លាប់

អ៊ំប្រុស **លី ខែម** ជាអ្នកថែរក្សាអង្គព្រៃទន្លាប់បានឱ្យដឹងថាកាលសម័យសម្តេចព្រះនរោត្តមសីហនុ គឺក្នុងឆ្នាំ១៩៦៨ ប្រជាជនក្នុងភូមិនាំគ្នានៅទៅជីកដីនៅទួលអង្គនោះដើម្បីលើករងដាំម្លូ ពេលនោះក៏ប្រទះឃើញក្រឡដែលមានគម្របដូចជាមកុដ ហើយនៅក្នុងក្រឡនោះមានឆ្អឹងខ្មោចពណ៌ខ្មៅ ប្រជាជនក៏នាំគ្នាយកក្រឡនោះទៅកប់វិញ។ ទន្ទឹមនឹងនោះ អ្នកភូមិខ្លះទៀតធ្លាប់ជីកឃើញអង្កាំបុរាណផងដែរកប់នៅទីនោះ។ ជាងនេះទៅទៀត មានបុរសម្នាក់នៅក្នុងភូមិ ពេលធ្វើផ្ទះបានទៅជីកយកថ្មមួយផ្ទាំងធំមកធ្វើជាជើងតាងទ្រជណ្តើរ ស្រាប់តែអ៊ំប្រុសពិនិត្យលើថ្មនោះឃើញមានឆ្លាក់អក្សរបុរាណគាត់ក៏ឱ្យគេយកទៅទុកនៅទួលនោះវិញ។[6]

សព្វថ្ងៃអង្គព្រៃទន្លាប់នេះ គឺត្រូវបានក្រុមគ្រួសារអ៊ំប្រុសជាអ្នកមើលថែរក្សា។ ការថែរក្សាទីនេះគឺដោយសារពីមុនមានពូរបស់គាត់ម្នាក់បានប្រាប់គាត់ឱ្យថែរក្សាកន្លែងអង្គនេះ ដោយគាត់ប្រាប់ថាមានជាតុរបស់សែស្រឡាយជីដូនជីតារបស់គាត់បានបញ្ចុះនៅទីនោះ។ ម្យ៉ាងគាត់មានផ្ទះនៅជិតកន្លែងអង្គនោះ និងពេលមើលថែទីកន្លែងនេះ ធ្វើឱ្យពួកគាត់ចេះតែសុខសប្បាយរហូតមក ហើយពេលមានជំងឺកើតឡើងគ្រាន់តែនឹកបន់ដល់អង្គនោះក៏ជា។



ទីតាំងទួលអង្គព្រៃទន្លាប់ដែលមើលពីចំងាយ



រោងអ្នកតានៅលើទួលអង្គព្រៃទន្លាប់

[6] **លី ខែម** អាយុ៧៩ឆ្នាំ រស់ក្នុងភូមិព្រៃខ្វាវ(បទសម្ភាសថ្ងៃ១៥ សីហា ២០១៦)

អង្គព្រៃទន្លាប់នេះ ពីដើមមានតែទួលពុំមានរោងអ្នកតាទេ ទើបតែអ៊ំស្រី **អ៊ូ ប៉ែត** បានទៅសង់។ មូលហេតុដែលសង់នោះ គឺដោយសារអ៊ំស្រីនៅសុខៗស្រាប់តែងឹតភ្នែកមើលមិនឃើញដោយមិនដឹងមូលហេតុ ដូច្នេះគាត់ក៏ទៅរកគ្រូទាយឱ្យមើល គ្រូទាយក៏ប្រាប់ថាដោយសារគាត់មិនដែលនឹកនាសែនដល់កន្លែងអង្គព្រៃទន្លាប់ទេ ដូច្នេះឱ្យធ្វើរោងអ្នកតាមួយបែរមុខទៅកើតហើយសែននិយាយបន់ស្រន់ទៅនឹងបានជាហើយ។ ក្រោយពេលអ៊ំស្រីរៀបចំសែនតាមក៏ស្រាប់តែភ្លឺភ្នែកវិញតែម្តង។ ចាប់ពីពេលនោះមកគាត់រឹតតែមានជំនឿចំពោះអង្គព្រៃទន្លាប់កាន់តែខ្លាំងឡើង។[7]

ប៉ុន្តែបើតាមបងស្រី **ងិន ណាវី** ត្រូវជាសាច់ញាតិរបស់អ៊ំ **លី ខែម** និង **អ៊ូ ប៉ែត** វិញថា ប្រជាជនក្នុងភូមិគេមិនគោរពឬជឿលើអង្គព្រៃទន្លាប់នេះទេ គឺមានតែសែស្រឡាយគ្រួសាររបស់បងស្រីប៉ុណ្ណោះដែលគោរព ដោយរៀងរាល់មុនថ្ងៃចូលឆ្នាំខ្មែរមួយថ្ងៃគឺនាំគ្នានិមន្តព្រះសង្ឃមកបង្សុកូល ប្រគេនចង្ហាន់តាមបែបបទព្រះពុទ្ធសាសនាដើម្បីឧទ្ទិសដល់បុព្វបុរស ជីដូនជីតាដែលបានចែកឋានទៅ។ ការបង្សុកូលនេះ គឺធ្វើតែមួយព្រឹកទេ ហើយហៅប្រជាជនក្នុងភូមិឱ្យមកចូលរួមដែរ។ ប្រជាជនដែលមកចូលរួមក៏មានយកចង្ហាន់ និងបច្ច័យមកប្រគេនព្រះសង្ឃផងដែរ។[8]

ដូច្នេះ ទោះបីជាប្រជាជនក្នុងភូមិមិនសូវមានជំនឿគោរពបន់ស្រន់ដល់អង្គព្រៃទន្លាប់ តែពួកគេក៏មិនដែលហ៊ានទៅធ្វើអ្វីឱ្យប៉ះពាល់ដល់កន្លែងនោះ ទេព្រោះពួកគេខ្លាចមានបារមីណាមួយមកធ្វើបាបដល់ពួកគេ ព្រោះអ្នកភូមិជាបុរសម្នាក់ធ្លាប់ឃើញរូបបុរសអសុកាយប៉ុនភ្នំដើរនៅជិតអង្គនោះ ហើយក៏មានអ្នកភូមិធ្លាប់ឃើញដុំភ្លើងធំៗហោះកាត់ដែរ។

**គ- អ្នកតាពែក**

អ្នកតាពែក គឺជាឈ្មោះរបស់អ្នកតាមួយកន្លែងនៅក្នុងភូមិព្រៃនេះដែរ ប៉ុន្តែប្រជាជននៅក្នុងភូមិពុំសូវមានជំនឿ និងគោរពខ្លាំងក្លា ដូចអ្នកតាសុខ និងអង្គព្រៃទន្លាប់នោះទេ។

ប្រវត្តិរបស់អ្នកតាពែកនេះកាលដើមឡើយមានឈ្មោះថា ត្រពាំងតាពែក ដោយសារនៅក្នុងភូមិនេះមានត្រពាំងមួយ ហើយថ្ងៃមួយមានតាម្នាក់ឈ្មោះតាពែក(ក្បាលគាត់ទំពែក) គាត់មានចរឹកអាឡិអាឡក់មិនសូវគ្រប់ទឹក បានដើរមកក្បែរត្រពាំងនេះហើយដួលស្លាប់។ ចាប់ពីពេលនោះមក ប្រជាជននាំគ្នាហៅត្រពាំងនោះថា ត្រពាំងតាពែក។ អ្នកភូមិខ្លះ អត់ហ៊ានដើរកាត់ទីនោះទេពេលយប់ ព្រោះខ្លាចខ្មោចតាពែកលង ហើយជួនកាលពេលដើរកាត់ គឺនឹកបន់សុំតាពែកកុំឱ្យលង។ ប៉ុន្តែមានប្រជាជនខ្លះទៀត គាត់មានជំនឿនៅកន្លែងអ្នកតាពែកនឹងថាស័ក្តិសិទ្ធិ ដោយគាត់ធ្លាប់បន់ស្រន់សុំអ្វីទៅវាបានសម្រេចដូចបំណង ហេតុដូច្នេះទើបអ្នកភូមិខ្លះនាំគ្នាសង់រោងអ្នកតាតូចមួយនៅក្បែរត្រពាំងនោះដើម្បីទុកជាទីសក្ការៈ។

ដូច្នេះយើងឃើញថា នៅក្នុងភូមិព្រៃខ្វាវតាំងពីដើមមក ប្រជាជនក្រៅពីការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ពួកគេនៅមានជំនឿផ្សេងៗទៅលើអ្នកតាម្ចាស់ស្រុក(អ្នកតាសុខ) ហើយក៏មានជំនឿតិចតួចជាមួយទួលអង្គបុរាណ ដូចជាអង្គព្រៃទន្លាប់ផងដែរ។ ទាំងនេះបង្ហាញឱ្យឃើញថា នៅក្នុងភូមិព្រៃខ្វាវទាំងមូល ការប្រតិបត្តិខាងសាសនា និងជំនឿអ្នកតាគឺផ្សារភ្ជាប់គ្នាមិនអាចកាត់ផ្តាច់ពីគ្នាបានទេនៅគ្រប់សម័យកាល។ គ្រាន់តែជំនឿនោះតិច ឬច្រើនទៅតាមពេលវេលាប៉ុណ្ណោះ។

---

[7] **អ៊ូ ប៉ែត** អាយុ៧៥ឆ្នាំ រស់ក្នុងភូមិព្រៃខ្វាវ (បទសម្ភាសន៍ថ្ងៃ១៥ សីហា ១០១៦)

[8] **ងិន ណាវី** អាយុ៣៥ឆ្នាំ រស់ក្នុងភូមិព្រៃខ្វាវ (បទសម្ភាសន៍ថ្ងៃ១៥ សីហា ១០១៦)




ទីតាំង និងរោងអ្នកតាពែក

## សន្និដ្ឋាន

ដូច្នេះតាមការសិក្សាស្រាវជ្រាវពីភូមិព្រៃខ្វាវនេះ យើងឃើញថាភូមិព្រៃខ្វាវ គឺជាភូមិមួយដែលបានកើតឡើងដោយមានប្រវត្តិសាស្ត្ររបស់ខ្លួនយ៉ាងច្បាស់លាស់។ តាំងពីសម័យមុនរហូតមកដល់បច្ចុប្បន្ន ប្រជាជនក្នុងភូមិមានការគោរពប្រតិបត្តិព្រះពុទ្ធសាសនា និងទំនៀមទម្លាប់របស់ខ្លួនយ៉ាងខ្ជាប់ខ្ជួនទោះបីជាសម័យឥឡូវមានឥទ្ធិពលនៃសាសនា និងវប្បធម៌របស់ជាតិសាសន៍ផ្សេងចូលមកយ៉ាងណាក៏ដោយ។ ជាមួយគ្នានេះ ជំនឿទៅលើអ្នកតាម្ចាស់ស្រុក ឬទួលអង្គដែលជាជំនឿតាមបែបបុរាណរបស់អ្នកស្រុកក៏នៅតែមាននៅក្នុងផ្នត់គំនិត និងស្មារតីរបស់ប្រជាជនភូមិព្រៃខ្វាវមួយចំនួនធំជាពិសេសក្នុងចំណោមមនុស្សចាស់ៗ ហើយអ្វីៗទាំងនោះវាបានបន្តរហូតមក។

ទាំងនេះបញ្ជាក់ឱ្យយើងឃើញថា ប្រជាជនភូមិព្រៃខ្វាវមានសេរីភាពយ៉ាងពេញលេញក្នុងការប្រតិបត្តិសាសនា និងជំនឿផ្សេងៗដោយពុំមានការហាមឃាត់ឡើយ ដែលជំនឿនិងការការគោរពទាំងអស់នោះវាបានរួមចំណែកដល់ការធ្វើឱ្យមានសន្តិភាពផ្លូវចិត្ត និងផ្លូវកាយដល់ប្រជាជន ហើយវាក៏ជួយធ្វើឱ្យមានសាមគ្គីភាពរវាងគ្នានិងគ្នានៅក្នុងភូមិទាំងមូលផងដែរ។

## ឯកសារពិគ្រោះ

- **អម អូន** អាយុ៧៥ឆ្នាំ ជាចាស់ទុំក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)
- **ប្រាក់ ណន** មេភូមិក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (សម្ភាសន៍ ថ្ងៃ១៥ សីហា ២០១៦)
- **លី ខែម** អាយុ៧៨ឆ្នាំ រស់ក្នុងភូមិព្រៃខ្វា វ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(បទសម្ភាស៍ថ្ងៃ១៥ សីហា ២០១៦)
- **អ៊ូ ប៉ែត** អាយុ៧៩ឆ្នាំ រស់ក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(បទសម្ភាសន៍ថ្ងៃ១៥ សីហា ១០១៦)
- **ឡាយ ពាប់** អាយុ៧៥ឆ្នាំ រស់នៅភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ(បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)
- **កែ សាម៉ុន** អាយុ៧០ រស់នៅភូមិព្រៃខ្វាវឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (បទសម្ភាសន៍ថ្ងៃ១៥ សីហា ២០១៦)
- **ងិន ណារី** អាយុ៣៨ឆ្នាំ រស់ក្នុងភូមិព្រៃខ្វាវ ឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ (បទសម្ភាសន៍ថ្ងៃ១៥ សីហា ១០១៦)